ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ **តាងនាមប្រជារាស្ត្រខ្មែរ**

លេខ : ៤៧ **តុលាការកំពូល**

ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៥

**សាលដីកា** បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៤ ខែ កញ្ញា

លេខ : ៧៥ ឆ្នាំ ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៥

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ជីវ កេង ចៅក្រម

៤- លោក យស់ សួខឿន ចៅក្រម

៥- លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក សាន សុជាត

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ៤១ "ឈ" ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៤៧ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

***ពិរុទ្ធ*** : ចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៣ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ ខេង សុភាព "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ កើត និង ទីលំនៅសព្វថ្ងៃភូមិចំបក ឃុំចំបក ស្រុកព្រែកប្រសប់ ខេត្តក្រចេះ ។ ឪពុកឈ្មោះខេង ប៉េងធីន "ស" ម្តាយឈ្មោះសៅ កុកងី "រ" ប្តីឈ្មោះប៉េង ឈាងឡាយ (លែងលះគ្នា) មានកូន០៤នាក់ ។ ក្នុងឃុំ ។

-មានមេធាវី លោក ប៊ិច វិច្ឆិកា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហ៊ុន សុខណៃ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ របររកស៊ីក្រុមហ៊ុននាំចេញនាំចូល ទីលំនៅសព្វថ្ងៃផ្ទះលេខ៧៦E₀ ផ្លូវលេខ១៣០ សង្កាត់

ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

-មានមេធាវី លោកស្រី ណេត ថាវីរ ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៤ របស់ឈ្មោះហ៊ុន សុខណៃ បានបញ្ជាក់ថា ខ្លួនសុំប្តឹងឈ្មោះខេង សុភាព ពីបទ : លួចមាសចំនួន១៨ជីម្ជីង កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៥ ដោយសំអាងហេតុថា ខ្លួនមានជំងឺហើយបានយកឈ្មោះខេង សុភាព នេះមកនៅជាមួយ ដើម្បីឱ្យជួយមើលថែខ្លួន ។ ដោយខ្លួនមានការទុកចិត្តលើឈ្មោះខេង សុភាព នេះ ទើបថ្ងៃមួយខ្លួនបានប្រើឈ្មោះនេះឱ្យលើកពូគយកទៅលើឡៅតឿ ហើយឆ្លៀតពេលនោះ ឈ្មោះខេង សុភាព បានលួចយកមាសរបស់ខ្លួនដែលទុកនៅលើឡៅតឿនោះ រួចហើយក៏រត់គេចខ្លួនទៅស្រុកកំណើតបាត់តែម្តង ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញ ថា : គ្មានភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទនោះទេ ដូចនេះ អយ្យការទុកសិទ្ធិឱ្យតុលាការពិចារណាវិនិច្ឆ័យឱ្យមានភាពយុត្តិធម៌ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១១៨"ឈ" ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-លើកលែងចោទប្រកាន់លើជនជាប់ចោទឈ្មោះខេង សុភាព ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ ឱ្យរួចផុតពីការចោទប្រកាន់ ពីបទ : ចោរកម្មប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌ ចែងឱ្យផ្តន្ទាទោសតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល យោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ។

២-សាលក្រមនេះ ជំនុំជំរះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះខេង សុភាព និង ដើមបណ្តឹងឈ្មោះហ៊ុន សុខណៃ បើភាគីណាមិនសុខចិត្ត និង សាលក្រមនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣៩"ឈ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះហ៊ុន សុខណៃ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១១៨"ឈ" ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : ជនជាប់ចោទពុំបានប្រព្រឹត្តដូចការចោទប្រកាន់របស់ដើមចោទទេ មហាអយ្យការសូមសន្និដ្ឋានចំពោះសាលាឧទ្ធរណ៍សំរេចតាមច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤១"ឈ" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ព្រះរាជអាជ្ញារង អមតុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ខែវិច្ឆិកា ឆ្នាំ២០០៤របស់ឈ្មោះហ៊ុន សុខណៃ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣-តំកល់សាលក្រមព្រហ្មទណ្ឌលេខ១១៨"ឃ" ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី ។

-បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៤៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ របស់ឈ្មោះហ៊ុន សុខណៃ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៤១"ឈ" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះហ៊ុន សុខណៃ (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ របស់ឈ្មោះខេង សុភាព (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : រឿងនេះឈ្មោះហ៊ុន សុខណៃ មានភស្តុតាងបន្ទាប់បន្សំ ដើម្បីធ្វើការដាក់បន្ទុកលើជនជាប់ចោទឈ្មោះខេង សុភាព ដូចជាសាក្សីឈ្មោះហ៊ុន សុខតាង , ហាង ឡោ និងចៅស្រីរបស់ខេង សុភាព ឈ្មោះខួច ។ រីឯឈ្មោះខេង សុភាពវិញគ្មានភស្តុតាងដោះបន្ទុកឡើយ ។ ដូច្នេះគប្បីបង្វិលសំណុំរឿងនេះទៅតុលាការថ្នាក់ក្រោមដើម្បីធ្វើការស៊ើបអង្កេតជាថ្មី ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះខេង សុភាព (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : នាងខ្ញុំពុំបានយកមាស ហ៊ុន សុខណៃ ទេ មាស៥ជី ជាមាសកូនរបស់នាងខ្ញុំ នាងខ្ញុំបានឆ្លើយថា នាងខ្ញុំគ្មានមាសទេ បើសិនជាមានមែន មាសនោះជាមាស សុខណៃហើយ នាងខ្ញុំមិនបាននិយាយជាមួយ សុខណៃ ថាយកមាសសង សុខណៃ វិញទេ ។ ពេលនាងខ្ញុំមកនៅភ្នំពេញ នាងខ្ញុំឱ្យកូននាងខ្ញុំដេកចាំផ្ទះឱ្យ កូននាងខ្ញុំពុំបានដឹងមុនថា សុខណៃ ទៅរុករកមាសនៅជង្រុកស្រូវនៅក្រចេះឡើយ ។ ហើយបានរុះរើជង្រុកស្រូវខុសប្លែកពីធម្មតានោះ ។ ពេលនាងខ្ញុំលើកពូកដាក់លើឡាវតឿ សុខណៃ ជាអ្នកបើកភ្លើងឱ្យនាងខ្ញុំក្រោយពីដាក់ពូកហើយ ក៏ចុះមកក្រោមទាំងអស់គ្នា ។

ដូច្នេះនាងខ្ញុំពុំបានយកមាស ហ៊ុន សុខណៃ ទេ សូមតុលាការលើកលែងចោទប្រកាន់នាងខ្ញុំទៅ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះហ៊ុន សុខណៃ (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ការលើកឡើងរបស់ ខេង សុភាព មិនពិត ឈ្មោះខេង សុភាព ពិតជាបានលួចមាសនាងខ្ញុំមែន ព្រោះ

នាងខ្ញុំមានសាក្សី ចៅស្រីរបស់ ខេង សុភាព ឈ្មោះខូច ថាយាយរបស់ខ្លួនមានមាសដុំធំៗ និងមានចំលើយ ខេង សុភាព ខ្លួនឯងបានឆ្លើយនៅចំពោះមុខនាងខ្ញុំថា ខ្លួនសុខចិត្តយកមាសមកឱ្យនាងខ្ញុំវិញ ដរាបណា ឱ្យនាងខ្ញុំសង្ខទាយមួយព្រឹកឱ្យខ្លួន ។ ពេលនិយាយនេះខ្ញុំមានសាក្សី ហ៊ុន សុខនាង ជាអ្នកដឹងលឺ ។ ក្រោយពីលួចមាសនាងខ្ញុំហើយ លុះស្អែកឡើងយកលេសថា ចៅរបស់ខ្លួនគ្រុនឈាម ហើយក៏ត្រឡប់ទៅស្រុកតែម្តង តាំងពីពេលនោះមក ខេង សុភាព មានជីវភាពធូធារមានលុយទិញមាស៥ជី និង យកលុយ១៥ម៉ឺនរៀលទៅលួសយកកូនដែលវាយគេមកវិញ ។ ដូច្នេះសូមតុលាការចោទប្រកាន់លើឈ្មោះខេង សុភាព និងបដិសេធសាលាឧទ្ធរណ៍ឱ្យនាងខ្ញុំដោយក្តីអនុគ្រោះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស្រី នេត ថាវីរ៍ ការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហ៊ុន សុខណៃ នៅពេលជំនុំជំរះថា : ឈ្មោះខេង សុភាព ក្រោយពីលួចមាសកូនក្តីនាងខ្ញុំហើយ គាត់មានជីវភាពធូធា ដូចសេចក្តីបញ្ជាក់របស់លោកមេឃុំចំបក់ ។ លុយ១០ម៉ឺនរៀល ដែលកូនក្តីនាងខ្ញុំឱ្យនោះ គឺ ខេង សុភាព ចាយអស់ មាស៥ជី របស់ ខេង សុភាព គឺ ខេង សុភាព យកលុយលួចបាននេះទៅទិញ ពុំមែនមាសរបស់កូនគាត់ទេ ។ នាងខ្ញុំមានសំលេងចៅស្រីឈ្មោះខូច ថតទុកជាខ្សែអាត់ ។ ដូច្នេះសូមតុលាការបង្វិលសំណុំរឿងនេះទៅតុលាការថ្នាក់ក្រោម ដើម្បីស៊ើបអង្កេតជាថ្មី ។

-បានស្តាបសេចក្តីសន្និដ្ឋានរបស់លោកប៉ិច វិច្ឆិកា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះខេង សុភាព នៅពេលជំនុំជំរះថា : រឿងនេះគ្មានភស្តុតាងចោទប្រកាន់លើកូនក្តីខ្ញុំបាទទេ ផ្អែកលើភស្តុតាងដូចជាលិខិតបញ្ជាក់របស់មេឃុំចំបក់ សាក្សីជាកូនក្មេងអាយុ៧ឆ្នាំ តុលាការពុំអាចយកមកពិចារណាទេ ។ ណាមួយរឿងនេះពុំមែនជាបទល្មើសជាក់ស្តែងសូមតុលាការលើកលែងចោទប្រកាន់លើឈ្មោះខេង សុភាព និង តម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : រឿងមានសាក្សី និង ភស្តុតាងបន្ទាប់បន្សំដាក់បន្ទុកលើជនជាប់ចោទឈ្មោះខេង សុភាព សូមក្រុមប្រឹក្សាជំនុំជំរះបង្វិលសំណុំរឿងឱ្យធ្វើការស៊ើបអង្កេតសាជាថ្មី ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី , ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## **តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៣ចុះថ្ងៃទី២៨ខែមីនាឆ្នាំ២០០៥របស់អ្នកស្រីហ៊ុន សុខណៃ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤.នៃច្បាប់ស្តីពី

ការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការលើកឡើងរបស់អ្នកស្រីហ៊ុន សុខណៃ ក្នុងសារណា ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ ថា ឈ្មោះខេង សុភាព បានលួចមាសរបស់ខ្លួនចំនួន១៨ជីម្លឹង ដោយអាងហេតុថា នៅពេលដែលខ្លួនប្រើឈ្មោះខេង សុភាព ឱ្យយកពូកទៅដាក់លើឡៅតឿ ឆ្លៀតពេលនោះ ខេង សុភាព បានលួចមាសខ្លួន ដែលទុកនៅទីនោះ ហើយចាប់ពីពេលនោះមក ឈ្មោះខេង សុភាព មានជីវភាពធូធារនោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

+ពុំមានភស្តុតាងដាក់បន្ទុកថា ឈ្មោះខេង សុភាព បានលួចមាសអ្នកស្រីហ៊ុន សុខណៃ ឡើយ ។ ម្យ៉ាងទៀតក្រោយពេលលើកពូកដាក់ឡៅតឿ ឈ្មោះខេង សុភាព ក៏រស់នៅជាមួយអ្នកស្រីហ៊ុន សុខណៃ រយៈពេលមួយសប្តាហ៍ទើបត្រឡប់ទៅស្រុកវិញ បន្ទាប់ពីបងប្អូនបានទូរស័ព្ទប្រាប់ថា ចៅគ្រូនឈាមតាមរយៈទូរស័ព្ទអ្នកស្រីហ៊ុន សុខណៃ ។

-យល់ឃើញថា ការដែលដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនៅពេលសវនាការនេះថា ជនជាប់ចោទជាអ្នកលួចមាសរបស់អ្នកស្រី ដោយអ្នកស្រីសំអាងថា ចៅរបស់ជនជាប់ចោទឈ្មោះខួច បានឆ្លើយប្រាប់ថា មានមាស១កញ្ចប់នៅជង្រុកស្រូវ ហើយមានមាសដែលដកហូតបានថ្មី១ពីផ្ទះជនជាប់ចោទចំនួនប្រាំជី និង ថាជនជាប់ចោទបានសារភាពនៅមុខអ្នកស្រីថា នឹងទៅយកមាសពីស្រុកមកប្រគល់ឱ្យអ្នកស្រីដោយសុំធ្វើបុណ្យសង្ឃទាន១ពេលនោះ ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដូចការអះអាងរបស់អ្នកស្រីទេ ពីព្រោះភស្តុតាងសំខាន់នៅត្រង់ថា តើមានសាក្សីណាបានឃើញផ្ទាល់ថា ជនជាប់ចោទបានលួចយកមាសពីកន្លែងដែលដើមបណ្តឹងរដ្ឋប្បវេណីទុកនោះទេ ហើយក៏ពុំមានភស្តុតាងណាបញ្ជាក់ថាមាស១៨តម្លឹងដែលដើមបណ្តឹងរដ្ឋប្បវេណីបាត់ត្រូវបានរកឃើញនូវចំណែកណាមួយនៅលើដៃជនជាប់ចោទនោះដែរ ។ ដូច្នេះទោះបីមានចំណុចខ្លះ ដែលធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានវិមតិសង្ស័យ ក៏ប៉ុន្តែពុំមានលទ្ធភាពណារកភស្តុតាងដាក់បន្ទុកអ្វីបន្ថែមទៀតបានទេ ហើយតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ជនជាប់ចោទត្រូវបានរួចខ្លួន ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៤១"ឈ" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

### *វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និង ជនជាប់ចោទ*

១-ទទួលបណ្តឹងសាទុក្ខលេខ៤៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ របស់អ្នកស្រីហ៊ុន សុខណៃ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៤១"ឈ"ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-បង្គាប់ឱ្យដោះលែងឈ្មោះខេង សុភាព ពីមន្ទីរឃុំឃាំងជាបន្ទាន់ បើសិនជននេះមិនត្រូវឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ ។

៤-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៥ និង ប្រកាលនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៥ ។